**ក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន**

**មេធាវី គង់ សំអុន និងមេធាវី Anta GUISSÉ**

រាជធានីភ្នំពេញ/ទីក្រុងប៉ារីស

ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 29-Apr-2019, 08:00
CMS/CFO: Sann Rada

**គោរពជូន៖** ចៅក្រម **និល ណុន** ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** ចៅក្រម និងក្រឡាបញ្ជី នៃអង្គជំនុំជម្រះសាលាដំបូង ព្រមទាំងភាគីក្នុងសំណុំរឿង ០០២/០២

**កម្មវត្ថុ៖** មតិយោបល់លើសំណើសុំធ្វើចំណាត់ប្រភេទឯកសារសម្ងាត់ឡើងវិញ

---

លោកប្រធានជាទីគោរព!

យើងខ្ញុំបានទទួលអនុស្សរណៈ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ របស់អង្គជំនុំជម្រះ មានចំណងជើងថា "ឯកសារសម្ងាត់នៅក្នុងសាលក្រមសំណុំរឿង ០០២/០២ ដែលស្នើសុំឲ្យមានការធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈ" (ឯកសារ E467)។ ក្នុងអនុស្សរណៈនោះ លោកប្រធានបញ្ជាក់ថា អង្គជំនុំជម្រះបានកំណត់អត្តសញ្ញាណឯកសារសម្ងាត់ចំនួន ១.៤៣៩ ក្នុងឧបសម្ព័ន្ធចំនួន ៤ ហើយអង្គជំនុំជម្រះស្នើឲ្យមានការធ្វើចំណាត់ប្រភេទឯកសារទាំងនេះឡើងវិញជាឯកសារសាធារណៈ (ឯកសារ E467 កថាខណ្ឌ ២)។ លោកប្រធានស្នើឲ្យយើងខ្ញុំផ្ដល់មតិយោបល់លើការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ យ៉ាងយូរបំផុតត្រឹមថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ (ឯកសារ E467 កថាខណ្ឌ ៦)។

ដូចលោកប្រធានជ្រាបស្រាប់ហើយ ដោយហេតុថាយើងខ្ញុំបានលើកឡើងជាច្រើនដងរួចមកហើយក្នុងពេលជំនុំជម្រះក្ដី យើងខ្ញុំគោរពគោលការណ៍សាធារណភាពនៃកិច្ចពិភាក្សាដេញដោល។ ក្រោយពីបានពិនិត្យមើលឯកសារនៅក្នុងឧបសម្ព័ន្ធមួយគ្រួសមក យើងខ្ញុំមិនជំទាស់នឹងការស្នើសុំធ្វើចំណាត់ប្រភេទឯកសារទាំងនេះឡើងវិញទេ។

យើងខ្ញុំឆ្លៀតឱកាសនេះសូមទាញចំណាប់អារម្មណ៍លោកប្រធានថា សេចក្តីសន្និដ្ឋានរបស់យើងខ្ញុំមួយចំនួន ដែលមិនមាននៅក្នុងឧបសម្ព័ន្ធនៃអនុស្សរណៈរបស់អង្គជំនុំជម្រះ នៅតែជាឯកសារសម្ងាត់ដដែល។ យើងខ្ញុំគិតថា គ្មានហេតុផលអ្វីត្រូវរក្សាទុកសេចក្តីសន្និដ្ឋានទាំងនេះជាឯកសារសម្ងាត់ទៀតទេ នៅដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី។ ដូច្នេះ យើងខ្ញុំស្នើសុំលោកប្រធានពិចារណាលើបញ្ហានេះ។ ឯកសារទាំងនេះមាន ដូចជា E9/4/10, E266/2, E286/1, E307/7, E319/47/1, E406, E408/3, E319/51/1, E434/1/1, E447/1, E441/3, E319/63/1។

សូមលោកប្រធានមេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

**មេធាវី គង់ សំអុន** **មេធាវី** Anta GUISSÉ